# ព្រឹត្តិបត្រព័ត៌មាន

# BI-WEEKLY BULLETIN

លេខទី៥៣ ឆ្នាំ២០២១ (ថ្ងៃទី២៦ ខែកក្កដា ដល់ទី០៨ ខែសីហា ឆ្នាំ២០២១)

CRF2021/053 (26 July to 08 August 2021)

## ព័ត៌មានអំពីវិស័យស្រូវអង្ករ *(Rice News Briefing)*

### ក្នុងប្រទេស (In Cambodia)



**ការបិទច្រកព្រំដែនវៀតណាម ធ្វើឱ្យតម្លៃស្រូវក្នុងស្រុកធ្លាក់ចុះ**

**Closed Vietnam borders drive down prices of rice on domestic markets**

*Phnom Penh Post: July 27, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

**ការប្រែប្រួលអាកាសធាតុ បណ្ដាលឱ្យការផលិតរបស់កសិកម្មនិងត្រីធ្លាក់ចុះ**

**Climate change sees decline in fish and agricultural produce**

*Khmer Times: July 27, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)





**បញ្ហាស្រូវធ្លាក់ថ្លៃ៖ រដ្ឋមន្ត្រីកសិកម្មបានស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យ បញ្ចេញថវិកាជួយទិញស្រូវពីកសិករ**

**Paddy price declined: MAFF asks MEF to release budget to buddy paddy rice from farmers**

*Cambonomist: July 28, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ត្រៀមថវិការួចជាស្រេច សម្រាប់បន្តផ្តល់ឥណទានប្រមូលទិញស្រូវពីប្រជាកសិករ នៅរដូវប្រមូលផលដ៏ខ្លីខាងមុខ**

**ARDB already prepared to continue loan for paddy purchasing from farmers in the up-coming harvested**

*Fresh News: July 28, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)





### ធនាគារអភិវឌ្ឍជនបទ និងកសិកម្ម ទទួលបាន៨០លានដុល្លារ សម្រាប់ឥណទានគាំទ្រវិស័យស្រូវអង្ករ

### ARDB receives $80 million in funding to support rice sector

*Khmer Times: July 30, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)



### CRF ជួបជាមួយ AMK ដើម្បីសិក្សាពីលទ្ធភាពផ្តល់ហិរញ្ញប្បទាន

### Trade body, MFI hatching plans to fund rice sector

*Phnom Penh Post: August 01, 2021*

ចុចទីនេះ ដើម្បីអានជាភាសាអង់គ្លេស (Click here to read in English)

ចុចទីនេះ ដើម្បីអានជាភាសាខ្មែរ (Click here to read in Khmer)



### ARDB ត្រៀមកញ្ចប់កម្ចីរួចរាល់សម្រាប់វិស័យស្រូវអង្ករ

### ARDB loans set for rice sector

*Phnom Penh Post: August 02, 2021*

ចុចទីនេះ ដើម្បីអានជាភាសាអង់គ្លេស (Click here to read in English)

ចុចទីនេះ ដើម្បីអានជាភាសាខ្មែរ (Click here to read in Khmer)



### ការបង្កបង្កើនផលស្រូវរដូវវស្សារបស់កសិករក្នុងឆ្នាំនេះ មានសន្ទុះលឿនជាងឆ្នាំមុន

### Rainy season rice harvesting this year speeding up more than last year

*Post Khmer: August 03, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)



### ការនាំចេញអង្ករធ្លាក់ចុះ២៧% តែតម្រូវការពីវៀតណាម និងចិន មានការកើនឡើង

### Rice exports plunge 27 percent but demand from China and Vietnam rises

*Khmer Times: August 03, 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)




## ក្នុងខែកក្កដា ឆ្នាំ២០២១ ការនាំចេញអង្កររបស់កម្ពុជាមានការកើនឡើង ចំនួន ៣,៥៣ភាគរយ

**Rice export in July 2021 rise up 3.53%**

---

*Ministry of Information: August 03, 2021*

ចុចទីនេះ ដើម្បីអាន ( Click here to read)



## ភ្លៀងធ្លាក់ខ្លាំងបង្កើនក្តីសង្ឃឹមធំសម្រាប់ដំណាំស្រូវដើមរដូវ

**Heavier rains raising big hopes for bumper early-season rice crop**

---

*Khmer Times: July 30, 2021*

ចុចទីនេះ ដើម្បីអាន ( Click here to read)

## ពូជស្រូវសែនក្រអូបកំពុងតែធ្វើពិពិធកម្ម

**Sen Kra Ob (SKO) is diversifying**

---

*Rasmei Kampuchea: August 05, 2021*

ចុចទីនេះ ដើម្បីអាន ( Click here to read)





## អន្តរជាតិ ( International )





ឥណ្ឌា និងប៉ាគីស្ថាន ( India and Pakistan )

## ការពន្យល់៖ សង្គ្រាមឥណ្ឌានិងប៉ាគីស្ថានលើស្លាក GI សម្រាប់អង្ករបាសម៉ាទី

**Explained: India and Pakistan’s war over GI tag for Basmati rice**

---

*The Week: July 26, 2021*

ចុចទីនេះ ដើម្បីអាន ( Click here to read)

## រដ្ឋាភិបាលផ្អាកមិនឱ្យដាំដុះស្រូវនៅដីសើម

**Gov’t bans rice growing in wetlands**

---

*The Independence: July 27, 2021*

ចុចទីនេះ ដើម្បីអាន ( Click here to read)





ប៉ាគីស្ថាន ( Pakistan )

## ចិនបញ្ឈប់ការនាំចូលអង្ករពីប៉ាគីស្ថានដោយសារបញ្ហាកូវីដ

## China stops rice import due to coronavirus, says Razak

*The News: July 28, 2021* — ចុចទីនេះ ដើម្បីអាន (Click here to read)

ជប៉ុន ( Japan )

## ដំណាំស្រូវនៅក្នុងប្រទេសជប៉ុនធ្លាក់ចុះ ៦៥០០០ ហិកតា នៅក្នុងឆ្នាំ២០២១

## Rice Paddies in Japan to Decrease by 65,000 Hectares in 2021

*Jen Jii: July 29, 2021* — ចុចទីនេះ ដើម្បីអាន (Click here to read)

ថៃ ( Thailand )

## អង្ករអាស៊ី - តម្លៃអង្ករថៃធ្លាក់ចុះទាបបំផុតក្នុងរយៈពេល២ឆ្នាំ ដោយសារបញ្ហាលុយបាតធ្លាក់ថ្លៃ និងតម្រូវការធ្លាក់ចុះ

## Asia rice-thai prices slide to two-year low on weaker baht, demand

*Successful farming: July 29, 2021* — ចុចទីនេះ ដើម្បីអាន (Click here to read)




កូរ៉េខាងត្បូង ( South Korea )

## កូរ៉េខាងត្បូងនឹងបញ្ចេញអង្ករ ៨ម៉ឺនតោន ក្នុងខែសីហា ដើម្បីដោះស្រាយបញ្ហាវិបត្តិ

## S. Korea to release 80,000 tons of rice in Aug. to cope with supply shortages

*Korea Herald: August 02, 2021* — ចុចទីនេះ ដើម្បីអាន (Click here to read)

វៀតណាម ( Vietnam )

## វៀតណាមគ្រោងនឹងស្តុកអង្ករទុក ខណៈដែលជំងឺកូវីដប៉ះពាល់ដល់កសិករ

## Vietnam plans to stockpile rice as coronavirus curbs hit farmers

*Reuters: August 03, 2021* — ចុចទីនេះ ដើម្បីអាន (Click here to read)



ឥណ្ឌា ( India )

## អត្រាអង្ករឥណ្ឌាបានធ្លាក់ចុះដល់ ៤-១/២ ឆ្នាំទាបបំផុត ដោយសារតម្រូវការទន់ខ្សោយ និងកង្វះនាវា

## India rates hit 4-1/2-year low on weak demand, ship shortage

*Reuters: August 05, 2021* — ចុចទីនេះ ដើម្បីអាន (Click here to read)

ឥណ្ឌា ( India )

## តម្រូវការខ្សោយ និងកង្វះកប៉ាល់ ប៉ះពាល់ដល់តម្លៃអង្ករឥណ្ឌា

## Weak Demand and Ship Shortage Hits Indian Rice Price

*Grain mart: August 06, 021*

ចុចទីនេះ ដើម្បីអាន ( Click here to read)





វៀតណាម ( Vietnam )

## ក្តីសង្ឃឹមនៃការនាំចេញអង្ករ ដើម្បីស្រោចស្រង់បន្ទាប់ពីការវាយលុយរបស់កូវីដ១៩

## Rice exports hoped to recover after COVID-19 controlled: insiders

*Viet Reader: August 06, 2021*

ចុចទីនេះ ដើម្បីអាន ( Click here to read)

# ព្រឹត្តិការណ៍/សកម្មភាព

Event/ Activity

## សន្និសីទសហគ្រិនកសិកម្មកម្ពុជា "គំនិតច្នៃប្រឌិតនៃកសិកម្ម សម្រាប់ការរីកចម្រើនប្រកបដោយចីរភាព"

## Cambodia Agripreneurs Conference within the topic of "Innovation of Agriculture for Sustainable Growth"




នាព្រឹកថ្ងៃពុធ ទី២៨ ខែកក្កដា ឆ្នាំ២០២១ **ឧកញ៉ា សុខ សារ៉ន** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមជាវាគ្មិនកិត្តិយសមួយរូប នៅក្នុងសន្និសីទសហគ្រិនកសិកម្មកម្ពុជា ក្រោមប្រធានបទ "គំនិតច្នៃប្រឌិតនៃកសិកម្មសម្រាប់ការរីកចម្រើនប្រកបដោយចីរភាព" ដែលរៀបចំឡើងដោយ JCI Entrepreneur Square ដែលរួមសហការរៀបចំជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា និងសមាគមអ្នកផលិតចំណីអាហារកម្ពុជា ក្រោមការគាំទ្រពីស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងអង្គការជាតិ អន្តរជាតិនានា រួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម សហគ្រិនខ្មែរ Feed Future, USAID, CAVAC ដែលសន្និសីទនេះ មានការចូលរួមជិត៣០០នាក់។

គោលបំណងសំខាន់នៃសន្និសីទដែលប្រមូលផ្តុំដោយវាគ្មិនកិត្តិយសសំខាន់ៗ និងសុទ្ធតែពាក់ព័ន្ធនៅក្នុងឆ្អឹងខ្នងនៃការអភិវឌ្ឍវិស័យកសិកម្មកម្ពុជានេះ គឺដើម្បីលើកបង្ហាញអំពីដំណើរការនៃវិស័យកសិកម្មកម្ពុជា នៅក្នុងបរិបទកូវីដ១៩ ដែលច្បាស់ណាស់ វិស័យកសិកម្មគឺជាវិស័យមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ហើយរយៈពេលប៉ុន្មានឆ្នាំនេះ វិស័យកសិកម្មកំពុងតែមានការរីកចម្រើនជាលំដាប់ទាំងខ្នាតតូចនិងខ្នាតមធ្យម។ យ៉ាងណាមិញ នៅពេល

ដំណាលគ្នាជាមួយនឹងការរីកចម្រើននេះ ការប្រកួតប្រជែង បញ្ហាប្រឈម ក៏ជាបញ្ហាមួយដែលវិស័យកសិកម្ម ត្រូវមានការគិតគូរ និងយល់ដឹងច្បាស់។ ប្រធានបទសំខាន់ៗចំនួន៤ ត្រូវបានលើកឡើងនៅក្នុងសន្និសីទនេះ រួមមាន៖

១-ដំណើរការ បញ្ហា និងឱកាសសម្រាប់វិស័យកសិកម្មកម្ពុជា

២-គោលនយោបាយអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាលឆ្នាំ ២០៣០ និងលខ័ណ្ឌតំរូវភូតគាមអនាម័យសំរាប់នាំចេញកសិកផល

៣-ករណីផ្សេងៗរបស់ធុរៈកិច្ចកសិកម្ម មេរៀន ឧបសគ្គ និងដំណើរឆ្ពោះតទៅមុខ

៤-កញ្ចប់ជំនួយគាំទ្រដល់សហគ្រិនកសិកម្មកម្ពុជា

ក្នុងនាមជាវាគ្មិនកិត្តិយសមួយរូប និងតំណាងឱ្យវិស័យស្រូវអង្ករកម្ពុជា ឧកញ៉ា សុង សារ៉ន ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមផ្តល់បទបង្ហាញអំពីស្ថានភាពនៃវិស័យស្រូវអង្ករកម្ពុជា ដែលរួមមានទាំងផលិតកម្មស្រូវ និងការនាំចេញអង្ករ ហើយក៏សង្កត់ធ្ងន់អំពីរបត់នៃការនាំចេញអង្ករកម្ពុជានាពេលចុងក្រោយនេះ ស្របតាមបរិបទកូវីដ១៩ ដែលបាននិងកំពុងបន្តញាំញីដល់វិស័យស្រូវអង្ករ។ ជាមួយនឹងការបង្ហាញជូនអ្នកចូលរួមឱ្យបានស្វែងយល់អំពីមូលដ្ឋានគ្រឹះនិងព័ត៌មានសំខាន់ៗនៃវិស័យស្រូវអង្ករ ឧកញ៉ា ប្រធានសហព័ន្ធ ក៏បានលើកជូនអំពីគោ លនយោបាយ និងយន្តការនៃការគាំទ្រនានារប ស់ រាជរដ្ឋាភិបាលកម្ពុជា មកលើវិស័យស្រូវអង្ករ។ ជាពិសេស ឧកញ៉ា ប្រធានសហព័ន្ធបានបន្ថែមអំពីថាតើ មានផែនការឬទិសដៅយ៉ាងណា សម្រាប់ការផ្តោតសំខាន់របស់វិស័យស្រូវអង្ករនាពេលអនាគត ដើម្បីអាចឱ្យអ្នកចូលរួមទាំងអស់ ដែលជាតួអង្គពាក់ព័ន្ធមិនថាផ្ទាល់ ឬប្រយោលនៅក្នុងវិស័យមួយនេះ បានទទួលជាចំណេះដឹងគ្រឹះ សម្រាប់យកទៅអនុវត្ត និងគិតគូរបន្តទៅមុខ។

សន្និសីទសហគ្រិនកសិកម្មកម្ពុជា បានបញ្ចប់ទៅដោយទទួលបានការចូលរួមសួរសំណួរ និងចម្លើយដ៏មានផ្លែផ្កានានា ជាពិសេស គឺការចែករំលែកចំណេះដឹង និងឯកសារនានាពីវាគ្មិនដែលបានបកស្រាយទាំងអស់។

Click here for English article:
Cambodia Agripreneurs Conference within the topic of "Innovation of Agriculture for Sustainable Growth"











# កិច្ចពិភាក្សា ស្វែងយល់ពីលទ្ធភាពផ្តល់ហិរញ្ញប្បទាន ដល់វិស័យស្រូវអង្ករ រវាងសហព័ន្ធស្រូវអង្ករកម្ពុជា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK

## CRF and AMK Microfinance discussed the feasibility of financing for Cambodia's rice sector as CRF's members

នាថ្ងៃព្រហស្បតិ៍ ទី២៩ ខែកក្កដា ឆ្នាំ២០២១ **ឧកញ៉ា ចាន់ សុឃាំង** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ( ស.អ.ក ) និងជាប្រធានគណៈកម្មាធិការប្រតិបត្តិទទួលបន្ទុកផ្នែកវិនិយោគ និងហិរញ្ញវត្ថុរបស់ ស.អ.ក និង **លោក លន់ យ៉េង** អគ្គលេខាធិការ ស.អ.ក បានជួបស្វាគមន៍ និងពិភាក្សាតាមរយៈប្រព័ន្ធអនឡាញ ជាមួយនឹងក្រុមការងារជាន់ខ្ពស់របស់**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** AMK ដើម្បីសិក្សាស្វែងយល់អំពីលទ្ធភា ពនៅក្នុងហិរញ្ញប្បទានសម្រាប់វិស័យស្រូវអង្ករ ជាពិសេសទៅដល់រោងម៉ាស៊ីនកិនស្រូវនិងសហគមន៍កសិកម្ម។

កិច្ចពិភាក្សាផ្តោះប្តូរយោបល់នេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ទាំងសហព័ន្ធស្រូវអង្ករកម្ពុជា និងសម្រាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ដោយឧកញ៉ា អនុប្រធានសហព័ន្ធ និង លោកអគ្គលេខាធិការ បានជំរាបជូនក្រុមការងារសិក្សាស្រាវជ្រាវ និងផ្នែកអភិវឌ្ឍពាណិជ្ជកម្មរបស់ AMK អំពីស្ថានភាពនៃវិស័យស្រូវអង្ករកម្ពុជា និងសក្តានុពលនៃរោងម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញ និងសហគមន៍កសិកម្ម ដែលជាសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា ហើយអ្វីដែលជាចាំបាច់មិនអាចខ្វះបាននោះគឺហិរញ្ញប្បទាន សម្រាប់ទាំងជាដើមទុនបង្វិល ការទ្រទ្រង់អាជីវកម្ម និងពង្រីកអាជីវកម្ម។

ជាមួយនឹងការស្វែងយល់អំពីបញ្ហាប្រឈម និងការលំបាកក្នុងការទទួលបាននូវហិរញ្ញប្បទានរបស់ រោងម៉ាស៊ីន និងសហគមន៍កសិកម្ម តាមរយៈកិច្ចពិភាក្សាផ្តោះប្តូរយោបល់ពីសហព័ន្ធស្រូវអង្ករកម្ពុជានាថ្ងៃនេះ ក្រុមការងាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នឹងចងក្រងនូវការវាយតម្លៃការសិក្សាស៊ីជម្រៅ ទៅលើសក្តានុពលនិងកាលានុវត្តភាពនាពេលបច្ចុប្បន្ន និងពេលអនាគតរបស់វិស័យស្រូវអង្ករកម្ពុជា ហើយនឹងបន្តឈានទៅដល់ការរៀបចំផែនការ ក្នុងការសម្រួល និងពង្រីកនូវការផ្តល់ទាំងហិរញ្ញប្បទាននិងឥណទានផ្សេងៗសម្រាប់វិស័យស្រូវអង្ករ។




សហព័ន្ធស្រូវអង្ករកម្ពុជាក៏សង្ឃឹមដែរថា ទៅថ្ងៃមុខ ការសហការលើការផ្តល់កម្ចី ក៏ដូចជាការទ្រទ្រង់ហិរញ្ញវត្ថុចំពោះវិស័យស្រូវអង្ករ ពីសំណាក់ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញ វត្ថុនឹងកើនឡើង បន្ថែមពីលើយន្តការរបស់រាជរដ្ឋាភិបាល តាមរយៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានដូចជា កញ្ចប់ឥណទានសម្រាប់បណ្តារោងម៉ាស៊ីនកិនស្រូវ និងក្រុមហ៊ុនកិនកែច្នៃ និងនាំចេញអង្ករ ដើម្បីប្រមូលទិញស្រូវ ពីបងប្អូនប្រជាកសិករ និងការធានាឥណទានផ្សេងទៀតផងដែរ។

Click here for English article:
CRF and AMK Microfinance discussed the feasibility of financing for Cambodia's rice sector as CRF's members

# សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "កិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនកម្ពុជា"

## Workshop on Cross- Border Trade Facilitaton in Cambodia




**លោកស្រី គីម ស្រីរ័ត្ន** អនុប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និង ជាប្រធានគណកម្មាធិការប្រតិបត្តិទីផ្សារនិងជំរុញការនាំចេញ បានដឹកនាំសមាជិកសមាជិកាសហព័ន្ធស្រូវអង្ករចំនួន ១៥ រូប ចូលរួមនៅក្នុងសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី កិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនកម្ពុជា "Cross- Border Trade Facilitation in Cambodia" តាមប្រព័ន្ធវីដេអូ។

នៅថ្ងៃទី២៨-២៩ ខែ កក្កដា ឆ្នាំ២០២១ ក្រោមមូលនិធិពិសេស សម្រាប់គម្រោងសហប្រតិបត្តិការមេគង្គ-ឡានឆាង (Lancang-Mekong Cooperation Special Fund) ក្រសួងពាណិជ្ជកម្មកម្ពុជា បានរៀបចំនូវសិក្ខាសាលាសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី កិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនកម្ពុជា "Cross- Border Trade Facilitation in Cambodia" តាមប្រព័ន្ធវីដេអូ ដែលមានការចូលរួមពីសមាជិកសមាជិកា សហព័ន្ធស្រូវអង្ករកម្ពុជា ដែលជាក្រុមហ៊ុននាំចេញ ក្រុមហ៊ុនដឹកជញ្ជូន និងក្រុមហ៊ុនភស្តុភារជាដើម ហើយនិងមានការចូលរួមពីភ្ញៀវកិត្តិយសដទៃទៀតសរុបប្រហែល១០០នាក់។

នៅក្នុងសិក្ខាសាលារយៈពេល២ថ្ងៃនេះ មានប្រធានបទសំខាន់ៗ សម្រាប់ការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដូចជា កិច្ចសម្រួលពាណិជ្ជកម្មតាមព្រំដែននៅតំបន់អាស៊ីប៉ាស៊ីហ្វិក, ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន ATIGA e-Form D, គម្រោងប្រើប្រាស់វិក័យបត្រសម្រាប់ធ្វើប្រតិវេទន៍ស្វ័យបញ្ជាក់ដើមកំណើតទំនិញទូទាំងអាស៊ាន (ASEAN-Wide Self Certification –AWSC) និង កិច្ចសម្រួលពាណិជ្ជកម្មរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា លើការការផ្លាស់ប្តូរទិន្នន័យប្រតិវេទន៍គយ អាស៊ាន (ASEAN Customs Declaration Docu- ment-ACDD) ក្រោមប្រព័ន្ធបញ្ជរតែមួយអាស៊ាន និងប្រព័ន្ធបញ្ជរតែមួយជាតិកម្ពុជា។




សិក្ខាសាលាចែករំលែកចំណេះដឹងនេះ ពិតជាមានសារៈសំខាន់ណាស់ ហើយបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំង ពីសមាជិក សមាជិកា នៃសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការស្វែងយល់អំពីនីតិវិធី និងការធ្វើបច្ចុប្បន្នភាពថ្មីៗស្របតាមបច្ចេកវិទ្យានិងនៅក្នុងបរិបទកូវីដ១៩ ដែលអ្វីៗគ្រប់យ៉ាង រួមទាំងការធ្វើពាណិជ្ជកម្មផងដែរនោះ បាននិងកំពុងតែអនុលោមទៅតាមការរស់នៅបែបគន្លងថ្មី (New Normal) ហើយអ្វីដែលពិសេសនោះគឺ សិក្ខាសាលានេះគឺផ្តោតលើការធ្វើពាណិជ្ជកម្ម នៅក្នុងអាស៊ាន ដែលស្រប ទៅនឹង ទិស ដៅ ដែលសហព័ន្ធស្រូវអង្ករកម្ពុជា បាននិងកំពុងតែដាក់ចេញពេល គឺការចាប់យកទីផ្សារអាស៊ាន សម្រាប់ការនាំចេញអង្កររបស់កម្ពុជា ដោយសារតែបញ្ហាការដឹកជញ្ជូនតាមផ្លូវសមុទ្រ ទៅកាន់ទីផ្សារធំៗ ដូចជាអឺរ៉ុបជាដើមនោះ នៅតែបន្តជាប់គាំង ដូច្នេះហើយ ទីផ្សារអាស៊ាន គឺជាទីផ្សារដ៏មានសក្តានុពលមួយ ដែលសហព័ន្ធស្រូវអង្ករ កម្ពុជា បាននិងកំពុងតែបន្តយកចិត្តទុកដាក់ជំរុញសមាជិក។

Click here for English article:
[Workshop on Cross- Border Trade Facilitation in Cambodia]

# តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
(Paddy price & FOB Price)

### តម្លៃស្រូវសើម នៅវាលស្រែ ដែលកំពុងប្រមូលផល តាមបណ្តាខេត្តមួយចំនួន

ថ្ងៃសុក្រ ទី០៦ ខែសីហា ឆ្នាំ២០២១

គិតជារៀល/គីឡូក្រាម

| ខេត្ត | ស្រុក | សែនក្រអូប | អូអឹម ៥៤៥១ | អ៊ីអ៊ែរ ៨៥ | ផ្សេងៗ |
|---|---|---|---|---|---|
| កំពង់ចាម | ជើងព្រៃ | 800-850 | 650-700 | | |
| | បាធាយ | | 680-710 | 650-700 | |
| | ព្រៃឈរ | | 650-700 | | |
| ត្បូងឃ្មុំ | អូរាំងឪ | | 690-700 | | |
| កំពង់ធំ | ស្ទឹងសែន | | 720-750 | | |
| | ស្ទោង | | 720-730 | | |
| | សន្ទុក | | 690-750 | | |
| | កំពង់ស្វាយ | | 710-750 | 670-690 | |
| | ប្រាសាទសំបូរ | | 710-730 | | |
| | សណ្តាន់ | | 700-730 | | |
| | បារាយណ៍ | 800-900 | 600-700 | | |
| | តាំងគោក | 820-850 | | | 750-770 |
| បាត់ដំបង | បាណន់ | 870-900 | | 700-710 | |
| | បវេល | 860-900 | 730-750 | | |
| | សង្កែ | 870-900 | | | 700-750 |
| | ឯកភ្នំ | | | 640-660 | |
| ពោធិសាត់ | ក្រគរ | 850-880 | 620-650 | | |
| | កណ្តៀង | 880-900 | 700-720 | | |
| បន្ទាយមានជ័យ | មង្គលបុរី | 870-900 | 650-700 | | |
| | ភ្នំស្រុក | 870-900 | 650-710 | 600-650 | |
| | ព្រះនេត្រព្រះ | | 650-710 | | |
| តាកែវ | អង្គរបុរី | | | 650-700 | |
| | កោះអណ្តែត | | 790-800 | 700-720 | |
| | គិរីវង្ស | | 790-800 | 700-720 | |

| ខេត្ត | ស្រុក | សែនក្រអូប | អូអឹម ៥៤៥១ | អ៊ីអ៊ែរ ៨៥ | ផ្សេងៗ |
|---|---|---|---|---|---|
| កណ្តាល | ល្វាឯម | | 700-720 | 650-700 | |
| កំពង់ឆ្នាំង | កំពង់ត្រឡាច | | 710-730 | | |
| | រលាប្អៀរ | | | | 800-850 |
| | បរិបូណ៌ | | 700-730 | | |
| កំពង់ស្ពឺ | បសេដ្ឋ | 870-900 | | | |
| ព្រៃវែង | ព្រះស្តេច | | 700-730 | 650-710 | |
| | កំពង់ត្របែក | | 700-720 | | |
| | មេសាង | | 700-720 | | |
| | ពារាំង | | 700-710 | | |
| | ពាមជរ | | 700-720 | | |
| | បាភ្នំ | | 690-720 | 680-700 | |
| | ស្វាយអន្ទរ | | 700-710 | | |
| | កំចាយមារ | | 690-710 | | |
| សៀមរាប | ក្រឡាញ់ | | 690-710 | | |

### ប្រភពទិន្នន័យ

- សហគមន៍កសិកម្មនៅតាមបណ្តាខេត្ត
  ១. ខេត្តកំពង់ចាម (071 381 8271 , 090 374 567, 088 600 9985)
  ២. ខេត្តត្បូងឃ្មុំ (089 568 232)
  ៣. ខេត្តកំពង់ធំ (089 448 497 , 089 879 058, 092 711 766, 097 488 3065, 078 576 321, 012 214 628, 078 576 321, 012 682 007, 097 807 7600, 092 795 040)
  ៤. ខេត្តបន្ទាយមានជ័យ (012 427 863, 089 461 316)
  ៥. ខេត្តបាត់ដំបង (012 824665, 071 4456855, 077 581427)
  ៦. ខេត្តពោធិសាត់ (017 495060)
  ៧. ខេត្តកំពង់ឆ្នាំង (092 651689092 627992)
  ៨. ខេត្តកំពង់ស្ពឺ (098 352074)
  ៩. ខេត្តកណ្តាល (015 685029, 093 384994)
  ១០. ខេត្តតាកែវ (017 571792 , 012 901543 , 016 547935 , 012 601417)
  ១១. ខេត្តព្រៃវែង (092 780367, 097 9070328, 092 138823, 095 755448, 088 4083002, 016 550228, 015 650915, 077 289541 , 088 8733377)
- Agribee Cambodia PLC ( 096 77 00 111 )


**សហព័ន្ធស្រូវអង្ករកម្ពុជា** ( Cambodia Rice Federation )

**ប្រធានក្រុមប្រឹក្សាភិបាល ( Chairman )**
*លោកឧកញ៉ា ហ៊ុន ឡាក់ ( Okhna Hun Lak )*

**ប្រធានសហព័ន្ធ ( President )**
*លោកឧកញ៉ា សុង សារ៉ន ( Okhna Song Saran )*

**អគ្គលេខាធិការ ( Secretary General )**
*លោក លន់ យ៉េង ( Mr. Lun Yeng )*

**រៀបរៀងដោយ ( Prepared by )**
*កញ្ញា សន ឆវីតី - មន្រ្តីសម្របសម្រួលទំនាក់ទំនង*
*( Ms. Sorn Chhorvyvatey - Communication Coordinator )*

+855 23 559 8999
info@crf.org.kh
www.crf.org.kh
www.facebook.com/cambodiaricefederation
twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation